# លោកជំទាវ ជូ ប៊ុនអេង៖ "ប្រទេសចិនសព្វថ្ងៃមានការរីកចម្រើនគ្រប់វិស័យជាងគេនៅលើពិភពលោក ដោយមានកំណើនសេដ្ឋកិច្ចគួរឲ្យកត់សំគាល់ ទន្ទឹមនឹងមានការលេចចេញនូវបញ្ហាជួញដូរមនុស្ស ដែលមានមេខ្យល់ជាអ្នកបោកបញ្ឆោតស្ត្រីខ្មែរ"

**(សៀមរាប)៖** ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាបមានរៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-ចិនលើកទី២ ដើម្បីពិភាក្សាសម្រេចសេចក្តីព្រាង នៃកិច្ចព្រមព្រៀង ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានគណៈប្រតិភូរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** និងគណៈប្រតិភូរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិនដឹកនាំដោយ **លោក ឆេន ស៊ីគូ អគ្គនាយករង នៃអគ្គនាយកដ្ឋានស៊ើបអង្កេត ក្រសួងសន្តិសុខសាធារណៈ** ។




**លោកជំទាវ ជូ ប៊ុនអេង** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានមានប្រសាសន៍ស្វាគមន៍ចំពោះ ការអញ្ជើញមកដល់របស់គណៈប្រតិភូចិន នៅលើទឹកដីខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជាដោយសុវត្ថិភាព។ **លោកជំទាវ** ក៏បានលើកសរសើរចំពោះកំណើនសេដ្ឋកិច្ចចិន ដែលមានការរីកចម្រើនគ្រប់វិស័យជាងគេនៅលើពិភពលោក ទាំងនៅអាស៊ី និងអឺរ៉ុប ហើយប្រទេសកម្ពុជា ក៏ជាប្រទេសដែលមានទំនាក់ទំនងជាមួយប្រទេសចិនផងដែរ ដោយមានការផ្សារភ្ជាប់ចំណងសាមគ្គីភាព ក្នុងរយៈកាលកន្លងមក ដូចជា សេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម និងទេសចរណ៍ជាដើម ហើយប្រជាជន នៃប្រទេសទាំងពីរក៏មានទំនាក់ទំនងជាមួយគ្នាយ៉ាងស្អិតរមួត។ **លោកជំទាវ** បានមានប្រសាសន៍បន្ថែមទៀត ទៅលើបញ្ហាការជួញដូរមនុស្សពីប្រទេសកម្ពុជាទៅប្រទេសចិនថា៖ **ទន្ទឹមនឹងនោះក៏លេចចេញនូវបញ្ហាការជួញដូរមនុស្ស ដែលមានមេខ្យល់ជាអ្នកបោកបញ្ឆោតស្ត្រីខ្មែរទៅរៀបការប្តី ជាជនជាតិចិន ហើយត្រូវបានគេរកឃើញជនរងគ្រោះជាបន្តបន្ទាប់ទាំងស្របច្បាប់ និងខុសច្បាប់ដែលជាកង្វល់យ៉ាងខ្លាំងដល់រដ្ឋាភិបាលប្រទេសទាំងពីរ ត្រូវតែរិះរកមធ្យោបាយទប់ស្កាត់ជាបន្ទាន់ បើយើងនៅតែបណ្តែតបណ្តោយតទៅទៀតដោយគ្មានដំណោះស្រាយអ្វីសោះ នោះវានឹងបង្កឲ្យមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរដល់ សេចក្តីសុខសុភមង្គលផ្លូវកាយផ្លូវចិត្តមនុស្ស ព្រមទាំងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។**



**គួរបញ្ជាក់ផងដែរថា** កិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីពិភាក្សាសម្រេចសេចក្តីព្រាង នៃកិច្ចព្រមព្រៀងស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានរយៈពេលចំនួន ០៣ថ្ងៃ គឺថ្ងៃទី២៤-២៦ ខែសីហា ឆ្នាំ២០១៦ ប្រព្រឹត្តទៅនៅខេត្តសៀមរាប បានលើយករបៀបវារៈចំនួន ០៣ គឺ៖

**១.ប្រជុំពិភាក្សាលើខ្លឹមសារ កិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។**

**២.ប្រជុំពិភាក្សាកិច្ចដំណើរការបទដ្ឋាន ការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះ។**

**៣.ប្រជុំពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពរួមក្រោមកិច្ចព្រមព្រៀងទ្វេភាគី។**

ចុងបញ្ចប់ នៃកម្មវិធី **លោកជំទាវ ជូ ប៊ុនអេង** បានមានប្រសាសន៍ជូនពរដល់កិច្ចប្រជុំពិភាក្សា មានដំណើរការដោយរលូនតាមការគ្រោងទុក និងសូមជូនពរដល់គណៈប្រតិភូទាំងអស់មានសេចក្តីសុខគ្រប់ប្រការ និងទទួលបានជោគជ័យនៅក្នុងជំនួបកិច្ចប្រជុំនេះ។

---

## លោក ឆេន ស៊ីគូ ៖ សម្តេចក្រឡាហោម និង ប្រធានក្រុមប្រឹក្សារដ្ឋចិន

## ត្រូវរក្សាស្ថិរភាព និងពង្រឹងកិច្ចសហប្រតិបត្តិការ ផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការជួញដូរមនុស្សឆ្លងដែនឲ្យទទួលបានលទ្ធផលជាក់ស្តែង

(សៀមរាប)៖ នៅក្នុងកិច្ចប្រជុំទ្វេភាគីកម្ពុជា-ចិនលើកទី២ ដើម្បីពិភាក្សាសម្រេចសេចក្តីព្រាង នៃកិច្ចព្រមព្រៀង ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានគណៈប្រតិភូរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** និងគណៈប្រតិភូរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនដឹកនាំដោយ **លោក ឆេន ស៊ីគូ អគ្គនាយករង អគ្គនាយកដ្ឋានស៊ើបអង្កេតនៃក្រសួងសន្តិសុខសាធារណៈ។**

**លោក ឆេន ស៊ីគូ** បានថ្លែងសន្ទរកថាចូលរួមប្រជុំពិភាក្សា ពិគ្រោះយោបល់នៅក្នុងការងារបង្ក្រាបការជួញដូរមនុស្ស ដែលបានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសទាំងពីរ ដែលមានបទល្មើសកើនឡើងជាលំដាប់។



រដ្ឋាភិបាលប្រទេសទាំងពីរ ត្រូវបន្តយកចិត្តទុកដាក់ ហើយរដ្ឋាភិបាលប្រទេសចិន បានធ្វើការផ្សព្វផ្សាយអំពីការងារបង្ក្រាបការជួញដូរមនុស្ស និងបង្កើតច្បាប់ចំនួនពីរដោយដាក់បទបញ្ញាឲ្យរដ្ឋាភិបាលធ្វើការបង្ក្រាប ហើយទទួលបានលទ្ធផលល្អប្រសើរ។



**លោក ឆេន ស៊ីគូ** មាន ប្រសាសន៍ទាក់ទងទៅនឹងទំនាក់ទំនង រវាងប្រទេសទាំងពីរថា: ប្រទេសចិន និងប្រទេសកម្ពុជាធ្លាប់ជាបងប្អូនល្អ មានទំនាក់ទំនង ដៃគូល្អជាមួយគ្នាតាំងពីយូរលង់ណាស់មកហើយ ទន្ទឹមនឹងមានការរីកចំរើន និងមានការផ្លាស់ប្តូររវាងប្រទេសទាំងពីរ បទល្មើសជាច្រើនក៏មានការកើនឡើង ដែលខាងប៉ូលីសមិនទាន់ធ្វើការបង្ក្រាបបទល្មើសតាមការបង្គាប់បញ្ជាពីថ្នាក់លើ ហេតុដូច្នេះថ្នាក់ដឹកនាំប្រទេសទាំងពីរដែលមាន **សម្តេចក្រឡាហោម ខឹម នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជា**

**ណាចក្រកម្ពុជា** និង **ប្រធានក្រុមប្រឹក្សារដ្ឋចិន ៖ "ត្រូវតែរក្សាស្ថិរភាព និងពង្រឹងកិច្ចសហប្រតិបត្តិការ ផ្លាស់ប្តូរព័ត៌មានទាក់ ទងនឹងការជួញដូរមនុស្សឆ្លងដែន ឲ្យទទួលបានលទ្ធផលជាក់ស្តែង"។ លោកមាន ប្រសាសន៍ទៀតថា៖** យោងតាមស្ថិតិពីភាគីចិនបានឲ្យ ដឹងថា ការជួញដូរស្ត្រីខ្មែរបានកើតមានឡើងនៅប្រទេស ចិនហើយស្ថាប័នប៉ូលីសប្រទេសទាំងពីរ បាន ធ្វើការ បង្ក្រាបឥតឈប់ឈរ។



រដ្ឋាភិបាលប្រទេសចិន ធ្លាប់បានចុះហត្ថលេខាជាមួយ បណ្តាប្រទេសផ្សេងៗដូចជា វៀតណាម មីយ៉ាន់ម៉ា និង ឡាវ កាលពីឆ្នាំទៅ។ រដ្ឋាភិបាលចិនបានអញ្ជើញភាគី កម្ពុជាទៅទស្សនៈកិច្ចប្រទេសចិន ដើម្បីពិគ្រោះពិភាក្សា លំអិត ហើយលើកទី២បានរៀបចំធ្វើឡើងនៅខេត្តសៀម រាប ដើម្បីកំណត់កិច្ចព្រមព្រៀងទ្វេភាគី តាមសំណើ ភាគីកម្ពុជា។

**លោក ឆេន ស៊ីគួ** បានលើកឡើងបន្តថាកិច្ច ពិភាក្សារវាងប្រទេសទាំងពីរ អាចឆ្លើយឆ្លងតាមរយៈ សារអេឡិចត្រូនិច (e-mail) ទៅវិញទៅមក រាល់ឯក សារពាក់ព័ន្ធទាំងនេះ ត្រូវមានការពិភាក្សាលំអិតបន្ថែម ទៀតពី ការរៀបចំធ្វើផែនការសកម្មភាពបន្តនៅឆ្នាំក្រោយ ទៀតហើយយើងមានឯកសារត្រៀមទុកដូចជា ផែនការ សកម្មភាព សំរាប់ចុះហត្ថលេខាដោយបែងចែកជាចំនួន ឆ្នាំ ដើម្បីបញ្ចប់នៅដើមឆ្នាំក្រោយ គឺនៅចុងឆ្នាំ២០១៦ ខែវិច្ឆិកា ដើម្បីបញ្ចប់ការងារទាំងអស់នេះជាមួយរដ្ឋាភិ បាលមានចំនួន ០៦តំបន់គោលដៅ បានធ្វើកិច្ចសហ ប្រតិបត្តិការ។ ចុងបញ្ចប់ លោកមានសេចក្តីសង្ឃឹម យ៉ាងមុតមាំថា កិច្ចប្រជុំនៅទីនេះដែលមានភាគីទាំងពីរ នឹងមានការឯកភាពគ្នា ដោយយើងទទួលបាននូវជោគ ជ័យនៅក្នុងភារកិច្ច ។



